# ពុទ្ធិកសមាគមវត្តខ្មែរម៉ូដេសតូ

## MODESTO CAMBODIAN BUDDHIST SOCIETY, INC.

1528/1538 Grimes Avenue, Modesto, California 95358
Phone: (209) 522-3138

## បុណ្យអភិសេកព្រះសិអារ្យមេត្រី សម្តេចជួន ណាតនិងសម្តេចឃោសានន្ទា

យើងខ្ញុំទាំងអស់គ្នាជាព្រះសង្ឃ អាចារ្យ គណៈកម្មការនិងពុទ្ធបរិស័ទចំណុះជើងវត្តខ្មែរម៉ូដេសតូទាំងមូល បានមូលមតិគ្នាជាឯកច្ឆ័ន្ទប្រារព្ធធ្វើបុណ្យអភិសេកព្រះសិអារ្យមេត្រី សម្តេចព្រះសង្ឃរាជ ជួន ណាត និងសម្តេចព្រះមហាឃោសានន្ទា ហង្ស និងសមិទ្ធផលផ្សេងៗក្នុងវត្ត។

អាស្រ័យហេតុនេះ អាត្មាភាព យើងខ្ញុំសូមនិមន្តព្រះតេជគុណគ្រប់ព្រះអង្គនិងគោរពអញ្ជើញ លោកយាយ លោកតា អស់លោក លោកស្រី អ្នកនាងកញ្ញា និងពុទ្ធបរិស័ទជិតឆ្ងាយ ព្រមទាំងសប្បុរសជនប្រុសស្រីទាំងអស់ មេត្តាចូលរួមកម្មវិធីបុណ្យនេះឲ្យបានច្រើនកុះករ និងអនុមោទនាយកកុសលផលបុណ្យតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។

## កម្មវិធីបុណ្យ

ថ្ងៃសៅរ៍១០កើត ខែវិសាខឆ្នាំថោះបញ្ចស័ក ព-ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង៥ល្ងាចជួបជុំព្រះសង្ឃនិងពុទ្ធបរិស័ទជិតឆ្ងាយនៅវត្តខ្មែរម៉ូដេសតូ ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូ**ត្រពុទ្ធាភិសេក** រួចនិមន្តព្រះតេជគុណ ស្វាយ រឹទ្ធី សម្តែងព្រះធម៌ទេសនា លុះព្រឹកឡើងថ្ងៃអាទិត្យទី៣០ខែឆ្នាំដដែលម៉ោង**១០និមន្តព្រះសង្ឃ**បិណ្ឌបាត ម៉ោង១០.៣០ ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីលនិងនិមន្ត ព្រះគ្រូមហាឃិន នឿនសម្តែង**ព្រះធម៌ទេសនា** ម៉ោង១១ វេរភត្តប្រគេនដល់ព្រះសង្ឃ រួចនិមន្តព្រះសង្ឃសូត្រពហុទេវ៉ាជាកិច្ចបញ្ចប់បុណ្យ។

ធ្វើនៅវត្តខ្មែរម៉ូដេសតូ ថ្ងៃពុធទី១២ ខែមេសា ឆ្នាំ២០២៣

| ព្រះចៅអធិការ | អាចារ្យសម្រាប់វត្ត | ប្រធានគណៈកម្មការនាយក |
|---|---|---|
| **ភិក្ខុ យិន សួង** | **ស៊ុន សុផន** | **វ៉ាន់ ព្រុំ** |